កុមាររៀន
កុមារចេះ
ក ១២៣

# ខ្ញុំចូលចិត្តពណ៌



**កម្មវិធីជាតិស្តីពីការសិក្សាកម្រិតថ្នាក់ដំបូង នៃក្រសួងអប់រំ យុវជន និងកីឡា**

រឿង ៖ **ខ្ញុំចូលចិត្តពណ៌**
និពន្ធដោយ ៖ **ហ៊ុន ធីតា**
វិចិត្ររូបភាពដោយ ៖ **ហ៊ុន គឹមយាន**

សៀវភៅនេះត្រូវបានបោះពុម្ពផ្សាយក្រោមអាជ្ញាប័ណ្ណ CC BY-SA ។

សៀវភៅនេះត្រូវបានបង្កើតឡើងសម្រាប់កម្មវិធីកុមាររៀនកុមារចេះ ដែលជាកម្មវិធីជាតិស្តីពីការសិក្សាកម្រិតថ្នាក់ដំបូងរបស់ក្រសួងអប់រំ យុវជន និងកីឡា ដោយមានការគាំទ្រពីជំនួយពីពលរដ្ឋអាមេរិក។

ដើម្បីស្វែងរកសៀវភៅនេះនិងសៀវភៅដទៃទៀតសម្រាប់កុមារ លោកអ្នកអាចចូលទៅកាន់ទំព័រហ្វេសប៊ុកកុមាររៀនកុមារចេះ

www.facebook.com/123komar




ឬគេហទំព័រ តោះអាន ឬទាញយកកម្មវិធីបណ្ណាល័យឌីជីថលតោះអាន

Let's Read
www.LetsReadAsia.org

ផ្លែប៉េងប៉ោះ និងផ្លែទទឹមមានពណ៌ក្រហម។ ខ្ញុំចូលចិត្តញ៉ាំផ្លែប៉េងប៉ោះ និងផ្លែទទឹម។



ផ្លែស្វាយទុំ និងផ្លែចេកណាំវ៉ា
មានពណ៌លឿង។ ខ្ញុំចូលចិត្តញ៉ាំ
ផ្លែស្វាយទុំ និងផ្លែចេកណាំវ៉ា។



ផ្លែក្រូចឃ្វិច និងមើមការ៉ុតមានពណ៌ទឹកក្រូច។ ខ្ញុំចូលចិត្តញ៉ាំផ្លែក្រូចឃ្វិច និងមើមការ៉ុត។



សណ្ដែកកួរមានពណ៌បៃតង។

ខ្ញុំចូលចិត្តញ៉ាំសណ្ដែកកួរ ដាក់ក្នុង
ក្នុងសម្លការី។





ស្ពៃក្ដោប និងឆៃថាវមានពណ៌ស។

ខ្ញុំចូលចិត្តញ៉ាំស្ពៃក្ដោប និងឆៃថាវ
ដាក់ក្នុងសម្លចាប់ឆាយ។



ផ្លែត្រប់ខ្ចីមានពណ៌ស្វាយ។
ខ្ញុំចូលចិត្តញ៉ាំត្រប់ដុត។



ផ្កាឈូកមានពណ៌ផ្កាឈូក។

ខ្ញុំចូលចិត្តដាក់ផ្កាឈូកថ្វាយព្រះ។



ទឹកសមុទ្រមានពណ៌ខៀវ។

ខ្ញុំចូលចិត្តមើលទឹកសមុទ្រ។



ខ្ញុំចូលចិត្តពណ៌នៅលើទង់ជាតិ
ប្រទេសកម្ពុជា។ ទង់ជាតិប្រទេស
កម្ពុជាមានបីពណ៌។



ខ្ញុំចូលចិត្តពណ៌ឥន្ទធនូ។
ឥន្ទធនូមានប្រាំពីរពណ៌។



ខ្ញុំចូលចិត្តប៉ោងប៉ោង។ ប៉ោងប៉ោងទាំងនេះ មានប្រាំបីពណ៌។





ពេលយប់មានពណ៌ខ្មៅ។
តើមានអ្វីផ្សេងទៀតដែលមាន
ពណ៌ខ្មៅ?

# សំណួរ

១. តើផ្លែឈើអ្វីដែលមានពណ៌លឿង?
២. តើតួអង្គនៅក្នុងរឿងនេះចូលចិត្តយក
ផ្កាឈូកទៅធ្វើអ្វី?
៣. តើមានអ្វីខ្លះទៀតដែលមានពណ៌ខ្មៅ?
៤. តើកូនចូលចិត្តពណ៌អ្វី?

សិស្សថ្នាក់ទី១ ដែលកំពុងរៀននៅចុងឆ្នាំសិក្សា និង
សិស្សថ្នាក់ទី២ ដែលកំពុងរៀននៅដើមឆ្នាំសិក្សា អាច
អានសៀវភៅរឿងនេះ ដើម្បីជាការហ្វឹកហាត់អំណាន
បន្ថែម ដោយមិនចាំបាច់មានអ្នកដទៃជួយឡើយ។
ទោះយ៉ាងណា សិស្សក៏អាចអានសៀវភៅរឿងនេះ
ជាមួយគ្រូបានដែរ ដោយពួកគេអាចមើល និងនិយាយ
អំពីរូបភាពនៅក្នុងសៀវភៅរឿងនេះហើយអានពាក្យ
និងតួអក្សរដែលពួកគេស្គាល់។
ដរាបណាសិស្សចាប់ផ្ដើមអានសៀវភៅកាន់តែឆាប់ គឺ
កាន់តែល្អសម្រាប់ពួកគេ។



កម្មវិធីជាតិស្ដីពីការសិក្សាកម្រិតថ្នាក់ដំបូង
នៃក្រសួងអប់រំ យុវជន និងកីឡា

បោះពុម្ពឆ្នាំ ២០២០